# កំណត់អំពីបញ្ហា

# ព្រះវិហារ



គណៈបេសកកម្មអចិន្ត្រៃយ៍នៃប្រទេសកម្ពុជា
ប្រចាំនៅសហប្រជាជាតិ

ÉDITIONS APSARA

ចំណងជើង :

**កំណត់អំពីបញ្ហាព្រះវិហារ**

កំរងឯកសារ

រៀបចំចងក្រងឡើងវិញតាមការប្រមូលផ្តុំនៃ
ឯកសារជាតិផ្សេងៗ

បោះពុម្ពផ្សាយដោយ

**គេហដ្ឋានផ្សាយអប្សរា**

Publié par / Reproduced by
**ÉDITION APSARA**
Montréal, Québec H1W 3G7
Téléphone : 514-596-0896
Télécopieur : 514-596-1423
Courriel / Email : apsara16@sympatico.ca

រៀបចំដំកល់ទុកត្រឹមត្រូវតាមច្បាប់នៅ
បណ្ណាល័យជាតិនិងមណ្ឌលដំកល់ឯកសារកេបិក
បណ្ណាល័យជាតិកាណាដា
*ត្រីមាសទី៣ គ.ស. ២០០១ ព.ស. ២៥៤៥*

Dépôt légal
Bibliothèque et archives nationales Québec
Bibliothèque nationale du Canada
3è trimestre 2001

ISBN 2-9222202-11-9

All Rights Reserved រក្សាសិទ្ធិគ្រប់យ៉ាង Tous droits réservés

# កំណត់អំពីបញ្ហា
# ព្រះវិហារ

## គណៈបេសកកម្មអចិន្ត្រៃយ៍នៃប្រទេសកម្ពុជា
## ប្រចាំអង្គការសហប្រជាជាតិ

*(ចំឡងឡើងវិញ)*

ម៉ុងរេអាល់, កេបិក
កាណាដា
**ឆ្នាំ ២០០១**

# កំណត់អំពីបញ្ហាព្រះវិហារ

## ១- ស្ថានភាពថានលេខានៃព្រះវិហារ

ព្រះវិហារតាំងនៅលើជួរភ្នំដងរែក ត្រង់ព្រំប្រទល់ចុងបំផុតនៃប្រទេសថៃនិងប្រទេសកម្ពុជា ។ ព្រះវិហារតាំងនៅលើខ្ពង់រាបកំពស់៦២៥ម៉ែត្រ តាមផែនទីភូមិសាស្ត្របារាំង បើតាមផែនទីភូមិសាស្ត្រអង់គ្លេស កំពស់៦១៦ម៉ែត្រ ។ (ផែនទីទាំងពីរនេះសុទ្ធតែពោលជាម៉ែត្រទាំងអស់) ។ ប៉ុន្តែអ្នកថានលេខាបារាំងនិងអង់គ្លេសបានព្រមព្រៀងគ្នាសន្និដ្ឋានថា ៖

ក/ ខ្ពង់រាបពីខាងជើងទៅខាងត្បូងមានប្រវែងជា៨០០និង៩០០ម៉ែត្រ ។

ខ/ តួប្រាសាទដែលសង់នៅត្រង់គែមខាងត្បូងបំផុត ពន្លូតទៅទិសខាងជើង ដោយថ្កល់ទៅទល់នឹងខាងជើងបំផុតនៃខ្ពង់រាប ។

គ/ នៅខាងត្បូង គឺថានៅត្រង់ជើងនៃតួប្រាសាទ ខ្ពង់រាបមានសភាពចោតត្រែងមកលើទីដីវាលកម្ពុជា ចំណែកឯត្រង់ទិសខាងជើងនៅទីបំផុតនៃខ្ពង់រាបដីទេរជំរាលទៅរកប្រទេសថៃ ។ រឿងនេះហើយដែលនាំឱ្យអ្នកកសាងប្រាសាទពន្លូតថ្កល់ជណ្តើរពីខាងជើងទៅខាងត្បូង ។

ឃ/ ខ្ពង់រាបមានសភាពរាបស្មើសុទ្ធសាធ ។

ង/ ខ្ពង់រាបរាប់ចូលក្នុងជួរកំពូលភ្នំ ហើយតាំងនៅត្រង់បន្ទាត់ដែលបែងចែកទឹក ។



# ២- ដើមកំណើតប្រាសាទបុរាណ

ប្រាសាទព្រះវិហារដែលឈ្មោះមានន័យថា “**បុគ្គលជាទីគោរព**” មានន័យថា “**អារាមជាទីគោរព**” ផ្សាយមកពីភាសាសំស្ក្រឹត “**វិហារ**” ពិតជារាប់ចូលយ៉ាងដាច់ខាតក្នុងកេរ្តិ៍បតិកភ័ណ្ឌខាងសិល្បៈនិងខាងប្រវត្តិសាស្ត្រខ្មែរ ។



អំពីរបៀបសំណង់វិញ លក្ខណៈគ្រប់បែបទាំងអស់នៃប្រាសាទ ដូចជាទម្រង់ផែនការ របៀបសំណង់ ដំណើរតាក់តែងលំអរូបផ្សេងៗ គឺជាសិល្បៈរបស់ខ្មែរទាំងស្រុង ឥតមានខ្ចីពីសិល្បៈបរទេសណាមួយដ៏តិចតួច យកមកបញ្ចូលលាយឡំឡើយ ។ ក្នុងរឿងសិលាចារិក អក្សរដែលចារឹកនៅទីនោះទាំងអស់ជាភាសាខ្មែរនិងជាភាសាសំស្ក្រឹតដែលជារបស់ផ្សាយចេញពីព្រះមហាក្សត្រខ្មែរឬពីឥស្សរជនជាន់ខ្ពស់ខ្មែរទាំងឡាយតាំងពី ***ព្រះបាទយសោវរ្ម័នទី១*** ដែលព្រះអង្គទ្រង់ជាអ្នកកសាងប្រាសាទអង្គររបូត មកដល់ ***ព្រះបាទសុរិយវរ្ម័នទី២*** ដែលព្រះអង្គទ្រង់ជាអ្នកកសាងប្រាសាទអង្គរវត្តនោះ ។ មានចារឹកជាច្រើន ខ្លះមានប្រយោជន៍យ៉ាងពិសេសសំរាប់ប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជាជាពិសេសដូចជាចារឹករបស់លោក **ទិវាករបណ្ឌិត** ជាព្រះរាជគ្រូនៃព្រះមហាក្សត្រិយ៍ខ្មែរឡាយដែលទ្រង់សោយរាជ្យបន្តព្រះសន្តតិវង្សតាំងពី ***ព្រះបាទហារសៈវរ្ម័នទី៣*** មក



***អង្គអវតាព្រះវិស្ណុទ្រង់គង់នៅលើសិរសានាគនៃសមុទ្រសាគរ***

ដល់***ព្រះបាទសុរិយវរ្ម័នទី២*** ។ រឿងទាំងនេះហើយបានបើកឱកាសឱ្យអាចបញ្ជាក់សំរេចលក្ខណៈទាំងឡាយនៃរបៀបសំណង់របស់ប្រាសាទអង្គរវត្តបាន ។

ឯច្រកចូលដ៏ធំទៅក្នុងប្រាសាទដែលមាននៅពីខាងជើងនោះ ឥតមានន័យអ្វីមួយឡើយ ។ តាមធម្មតា ប្រាសាទនេះគឺសង់តាមគោលដែលទាក់ទងនឹងដីជារបស់ខ្មែរទាំងស្រុង នៅសម័យអង្គរ ។

ពិពណ៌នានៃប្រាសាទជាកម្មវត្ថុនៃសេចក្ដីជូនដំណឹងពិសេសមួយ (ឧបសម្ព័ន្ធទីមួយ) ។




*ក្រដាស់ប្រាក់ខ្មែរ*
*នៅជំនាន់ទសវត្សរ៍៦០*

## ៣- ការរំលឹកខាងប្រវត្តិសាស្ត្រ

ការពិនិត្យរឿងព្រះវិហារនេះ តំរូវឱ្យពោលដល់សន្ធិសញ្ញាដែលមានតៗមកដោយសង្ខេបនៅសម័យជាមួយគ្នារវាងប្រទេសបារាំងនិងប្រទេសសៀម ។



ដូច្នេះ គេចាំបានថាពីឆ្នាំ១៨៦៣ មកឆ្នាំ១៩៥៣ ប្រទេសកម្ពុជាជាប្រទេសអាណាព្យាបាលបារាំងក្នុងដែនដីឥណ្ឌូចិនបារាំងដែលមានលោក *គូវរណឺហ្សេណេរ៉ាល* អាស្រ័យនៅក្រុងហាណូយជាប្រមុខ ។

របៀបគ្រប់គ្រងនៃប្រទេសអាណាព្យាបាល បានប្រគល់នយោបាយប្រទេស នៃប្រទេសកម្ពុជាទៅលើប្រទេសបារាំង ។

អ្វីទាំងអស់ដែលស្ដីពីការទាក់ទងនៃប្រទេសកម្ពុជាជាមួយបរទេស ស្ថិតនៅក្រោមរាជការបារាំង ។

ដូច្នេះ ប្រទេសបារាំងត្រូវទាក់ទងជាមួយប្រទេសសៀម(ប្រទេសថៃសព្វថ្ងៃ) ជាប្រទេសមានព្រំប្រទល់ដែនជាប់គ្នានឹងដែនដីឥណ្ឌូចិនដែលមានប្រទេសកម្ពុជាជាដើមនោះ ។

**១- *សន្ធិសញ្ញាចុះថ្ងៃទី១៥សីហា១៨៥៦:***

(សន្ធិសញ្ញាពាណិជ្ជកម្មរវាងប្រទេសបារាំងនិងប្រទេសសៀម) ។

**២- *សន្ធិសញ្ញាចុះថ្ងៃទី១៥កក្កដា១៨៦៧:***

ប្រទេសសៀមទទួលស្គាល់អាណាព្យាបាលបារាំងលើប្រទេសកម្ពុជា ។

ប្រទេសបារាំងព្រមប្រគល់ខេត្តទាំងពីរ គឺបាត់ដំបងនិងសៀបរាប ឱ្យប្រទេសសៀម ។

**៣- *សន្ធិសញ្ញាចុះថ្ងៃទី៣តុលា១៨៩៣:***

ប្រទេសសៀមឈប់ក្តួចកាន់ប្រាថ្នាចង់បានទឹដីទាំងអស់ដែលស្ថិតលើត្រើយខាងឆ្វេងនៃទន្លេមេកុង និងលើកោះទាំងឡាយនៃទន្លេនោះ ។ សៀមសន្យាមិនដាក់កងកម្លាំងទ័ពអ្វីមួយនៅក្នុងខេតបាត់ដំបងនិងខេត្តសៀបរាបឡើយ ។

***៤- អនុសញ្ញាចុះថ្ងៃទី១៣កុម្ភៈ១៩០៤:***

នេះជាអត្ថបទប្រកបដោយសារៈ ។ អត្ថបទនេះមានវត្ថុបំណងជាអាទិ៍ដើម្បីបញ្ជាក់នូវបន្ទាត់ដ៏ត្រឹមត្រូវពិតប្រាកដនៃព្រំប្រទល់ដែនរវាងប្រទេសសៀមនិងប្រទេសកម្ពុជា ។ ប្រការទី១នៃអនុសញ្ញានេះជាកម្មវត្ថុពិសេស ។

*ប្រាសាទព្រះវិហារគោប៉ូរៈទី២*



**ប្រការទី១.-** ព្រំប្រទល់ដែនរវាងប្រទេសសៀមនិងប្រទេសកម្ពុជា ប្រព្រឹត្តទៅតាមត្រើយខាងឆ្វេងនៃទន្លេសាបពីមាត់ពាមស្ទឹងរលួសទៅ ព្រំប្រទល់ដែននេះប្រព្រឹត្តទៅស្របគ្នានឹងចំណុចខាងលើទៅទិសខាងកើត រហូតដល់ស្ទឹងព្រែកកំពង់ចាម រួចងាកទៅខាងជើង ប៉ះនឹងខ្សែខណ្ឌចំណុចខាងលើ ឡើងរហូតដល់ជួរភ្នំដងរែក ។ ពីទីនេះទៅ**ព្រំប្រទល់ដែនប្រព្រឹត្តតាមបន្ទាត់បែងចែកទឹករវាងទន្លេណាំសេននឹងទន្លេ មេកុងមួយផ្នែកនិងទន្លេណាំមួនមួយផ្នែកហើយទៅភ្ជាប់នឹងជួរភ្នំប៉ាដង់ ដែលប្រព្រឹត្តទៅតាមកំពូលភ្នំត្រង់ទៅទិសខាងកើតរហូតដល់ទន្លេមេកុង** ។ នៅខាងលើទឹកនៃចំណុចនេះទន្លេមេកុងស្ថិតនៅជាព្រំប្រទល់ដែននៃព្រះរាជអាណាចក្រសៀមដោយអនុលោមតាមប្រការទី១នៃសន្ធិសញ្ញា ចុះថ្ងៃទី៣តុលា១៨៩៣ ។

**ប្រការទី៣.**- នឹងត្រូវកំណត់ព្រំប្រទល់ដែនរវាងដែនដីទាំងឡាយនៃប្រទេសឥណ្ឌូចិនបារាំងនិងព្រះរាជអាណាចក្រសៀម ។ គណៈកម្មការចំរុះទាំងឡាយមាននាយទាហានជាសមាជិកហើយដែលប្រទេសជាប់កិច្ចសន្យាទាំងពីរ ជាអ្នកតែងតាំងនោះត្រូវរៀបចំកំណត់ព្រំដែននេះ... ។

បទបញ្ញត្តិទាំងនេះ និងបទបញ្ញត្តិដែលមានតទៅទៀត ក្នុងអនុសញ្ញា នឹងលើកយកមកពោលយ៉ាងពិស្តារក្នុងអង្គសេចក្តីជូនដំណឹងបច្ចុប្បន្ននេះ ។

**៥- សន្ធិសញ្ញាចុះថ្ងៃទី២៣មិនា១៩០៧:**

ប្រទេសសៀមបានប្រគល់ត្រឡប់ឱ្យមកប្រទេសបារាំងវិញ គឺថាឱ្យមកប្រទេសកម្ពុជា នូវខេត្តបាត់ដំបង សៀមរាប និងស៊ីសូផុន ដែលព្រំប្រទល់ដែនដ៏ទៀងទាត់មានសំរេចរួចហើយជាស្រេចក្នុងខទាំងឡាយនៃពិធីការដែលដាក់ជាប់ជាមួយសន្ធិសញ្ញាស្រាប់ ។

ចំណែកប្រទេសបារាំងក៏បានប្រគល់ឱ្យទៅប្រទេសសៀម នូវខេត្តដាន់សាយ និងខេត្តត្រាត់ ព្រមទាំងកោះទាំងអស់ដែលស្ថិតនៅខាងត្បូងជ្រោយឡែនលឹង ដោយរាប់ចូលទាំងកោះកុតផង ។ សន្ធិសញ្ញាបានចែងថា ការកំណត់ព្រំដែនដ៏ជាក់លាក់នៃដែនដីទាំងឡាយដែលប្រគល់ឱ្យមកនេះនឹងត្រូវគណៈកម្មការចំរុះមួយជាអ្នកធ្វើក្នុងរយៈពេល៤ខែតាមការសច្ចាប័ន្ននៃសន្ធិសញ្ញា ។

ពិធីការដែលដាក់ភ្ជាប់មកនឹងសន្ធិសញ្ញាបញ្ជាក់នូវចំណុចដ៏ធំៗទាំងឡាយនៃការកំណត់ព្រំប្រទល់ដែនដើម្បីឱ្យគណៈកម្មការការងារនឹងធ្វើការនោះ ។ ចាប់ពីចំណុចមួយដែលស្ថិតនៅលើភ្នំដងរែកទៅដល់ពាក់កណ្តាលផ្លូវជាចន្លោះច្រកឈ្មោះចុងតាកោ និងច្រកឈ្មោះចុងសាថេត ព្រំប្រទល់ដែនប្រព្រឹត្តទៅតាមបន្ទាត់បែងចែកទឹករវាងទន្លេសាប និងទន្លេមេកុងមួយផ្នែក ហើយនិងទន្លេណាំមួនមួយផ្នែក រួចទៅដល់ទន្លេមេកុងជាខាងក្រោមប៉ះមួន ត្រង់មាត់ពាមវ៉ៃខូ **ដោយអនុលោមតាមតម្រាយដែលគណៈកម្មការខាងការចែកព្រំដែនលើកមុនកាលពីថ្ងៃទី១៩មករា១៩០៧ បានអនុម័តនោះ** ។

គំនូសព្រាងសង្ខេបនៃព្រំប្រទល់ដែនដូចបានពណ៌នាខាងលើនេះមានដាក់ជាប់មកនឹងពិធីបច្ចុប្បន្ននេះ ។

**៦- សន្ធិសញ្ញាខាងមិត្តភាពខាងពាណិជ្ជកម្មនិងកងនាវាចរ ចុះថ្ងៃទី១៤កុម្ភៈ១៩២៥ ៖** សន្ធិសញ្ញានេះបញ្ជាក់បន្ថែមនិងធានាចំពោះព្រំប្រទល់ដែនដែលបានស្ថាបនាហើយ ក្នុងពេលមុន រវាងដែនដីប្រទេសកម្ពុជានិងប្រទេសសៀម ដោយអនុលោមតាមកិច្ចព្រមព្រៀងពីមុនមកហើយ **ដែលនៅជាធរមានយ៉ាងត្រឹមត្រូវនៅឡើយ (ប្រការទី២)** ។

ក្នុងអនុសញ្ញានេះ មានចែងសេចក្តីថា ការស្មុគ្រស្មាញទាំងឡាយដែលមិនអាចដោះស្រាយបានតាមផ្លូវទូត ឬតាមកិច្ចព្រមព្រៀងសំរុះសំរួលណាមួយនោះ ត្រូវដាក់ជូនទៅឱ្យអ្នកអាជ្ញាកណ្តាលម្នាក់ឬច្រើននាក់ ជួយវិនិច្ឆ័យឬបើគ្មានអ្នកអាជ្ញាកណ្តាលទេត្រូវដាក់ជូនទៅ**សាលាតុលាការអចិន្ត្រៃយ៍អន្តរជាតិ**(ប្រការទី២) ។



*ភ្នំព្រះវិហារ*

ប្រការទី២៧នៃសន្ធិសញ្ញាក៏មានចែងសេចក្តីដូច្នេះទៀតថា សន្ធិសញ្ញានេះអាចលប់ចោលនូវសន្ធិសញ្ញាដទៃ អនុសញ្ញា និងការសំរុះសំរួលទាំងឡាយដែលបានធ្វើរួចហើយ រវាងប្រទេសបារាំងនិងប្រទេសសៀមបាន វៀរលែងតែខទាំងឡាយដែលទាក់ទងចំពោះសេចក្តីសំរេច ហើយ និងការកំណត់ព្រំប្រទល់ដែនដែលមាននៅក្នុងសន្ធិសញ្ញា ចុះថ្ងៃទី៣តុលា១៨៩៣ ក្នុងអនុសញ្ញាចុះ ថ្ងៃទី១៣កុម្ភៈ១៩០៤ និងក្នុងសន្ធិសញ្ញាចុះថ្ងៃទី២៣មិនា១៩០៧ ហើយនិងពិធីការរបស់ខ្លួនដែលនៅជាប់ជាមួយនោះចេញ ។

**៧- អនុសញ្ញាចុះថ្ងៃទី២៩សីហា១៩២៦ ៖** អនុសញ្ញានេះ សំរេចនូវការកំណត់ព្រំប្រទល់ដែនខាងទន្លេមេកុងរវាងប្រទេសសៀមនិងប្រទេសឥណ្ឌូចិន ហើយបង្កើតឱ្យមានសហប្រតិបត្តិការមួយរវាងប្រទេសទាំងពីរ ខាងក្រុមព្រះនគរបាល និងខាងសន្តិសុខនៅតាមទន្លេ ។

**៨- សន្ធិសញ្ញាមិត្តភាពខាងពាណិជ្ជកម្មនិងនាវាចរ ចុះថ្ងៃទី៧ធ្នូ១៩៣៧ ៖** សន្ធិសញ្ញានេះបញ្ជាក់បន្ថែមជាថ្មី

លើព្រំប្រទល់ដែនខ្មែរ-សៀម ដែលបានកំណត់ទុករួចហើយពីពេលមុន ព្រមទាំងរក្សាទុកឱ្យនៅជាធរមានយ៉ាងដាច់ខាត ចំពោះចំណុចនេះនូវ **អនុសញ្ញា១៩០៤** និង **អនុសញ្ញា១៩០៧** (ប្រការទី២២) ។

**៩- អនុសញ្ញាសន្តិភាពរវាងប្រទេសបារាំងនិងប្រទេសសៀម(ថ្ងៃទី៩ឧសភា១៩៤០) ៖** អនុសញ្ញានេះបានទទួលការចុះហត្ថលេខានៅក្រុងតូក្យូតាមអន្តរាគមន៍នៃប្រទេសជប៉ុនដែលបានតំរូវឱ្យមានយុទ្ធសន្តិភាព ដើម្បីបញ្ឈប់ការប្រទូស្តរាយដែលប្រទេសថៃបានប្រព្រឹត្តប្រឆាំងនឹងប្រទេសកម្ពុជា គឺថាប្រឆាំងនឹងបារាំងនេះឯង ក្នុងខែវិច្ឆិកា១៩៤០ ។

តាមអនុសញ្ញានេះ រដ្ឋាភិបាលបារាំងនៅក្រុងវីស្ហី ដោយមានការបង្ខំពីប្រទេសជប៉ុន បានត្រូវលះបង់ចោលនូវខេត្តខ្មែរផ្នែកខាងលិច គឺខេត្តបាត់ដំបង កំពង់ធំមួយភាគ ខេត្តស្ទឹងត្រែង និង ខេត្តសៀមរាប ។ ហេតុដូច្នេះ អនុសញ្ញានេះបានកែប្រែព្រំប្រទល់ដែនរវាងឥណ្ឌូចិន និងប្រទេសថៃ (ប្រការ២) ។

**១០- កិច្ចព្រមព្រៀងប៉ារាំង-សៀមដែលទទួលការចុះហត្ថលេខានៅថ្ងៃទី១៧វិច្ឆិកា១៩៤២ នាក្រុងវ៉ាស៊ីនតោន ៖**

កិច្ចព្រមព្រៀងនេះរំលាយចោលនូវអនុសញ្ញា ចុះថ្ងៃទី៩ឧសភា១៩៤០ ដែលរដ្ឋាភិបាលបារាំងបានបដិសេធចោលក្នុងពេលមុខ ហើយស្តាបនាជាថ្មីឡើងវិញនូវច្បាប់ចាស់ដែលកើតមានមុនអនុសញ្ញានេះ (ប្រការ២) ។

ប្រការ២ បញ្ជាក់ថា **ហេតុដូច្នេះ ដែនដីឥណ្ឌូចិនជាកម្មវត្ថុនៃអនុសញ្ញានេះត្រូវផ្ទេរមកឱ្យរាជការបារាំង ។** កិច្ចព្រមព្រៀងបញ្ជាក់ថា**កិច្ចប្រាស្រ័យទាក់ទងខាងការទូតបានត្រូវស្តាបនាឡើងវិញហើយការទាក់ទងរវាងប្រទេសបារាំងនិងប្រទេសសៀមក៏ត្រូវមានជាថ្មីឡើងវិញតាមសន្ធិសញ្ញាចុះថ្ងៃទី៧ធ្នូ១៩៣៧** ។ កិច្ចព្រមព្រៀងបានបញ្ជាក់ម៉្យាងទៀតថា **ខាងក្រោយការផ្ទេរទឹកដីដែលបានប្រគល់ឱ្យក្នុងពេលមុនម្តងហើយនោះ មានគណៈកម្មការបង្រួបបង្រួមមួយបានទទួលការពិនិត្យគ្រឿងសំអាងខាងជាតិពិន្ទុខាងភូមិសាស្ត្រនិងខាងសេដ្ឋកិច្ចនៃគូវិវាទ ដើម្បីរើពិនិត្យជាថ្មី ឬបញ្ជាក់បន្ថែមនូវខទាំងឡាយនៃសន្ធិសញ្ញាចុះថ្ងៃទី១តុលា១៩៣៣នៃអនុសញ្ញាចុះថ្ងៃទី១៣កុម្ភៈ១៩០៤ និង សន្ធិសញ្ញាចុះថ្ងៃទី២៣មិនា១៩០៧ ដែលសន្ធិសញ្ញាចុះថ្ងៃទី៧ធ្នូ១៩៣៧(ប្រការ៣) បានរក្សាទុកឱ្យនៅជាធរមាន** ។ គណកម្មការនេះបានរួមប្រជុំគ្នានៅឆ្នាំ១៩៤៧ ។ ក្រោយការពិនិត្យបញ្ហាដ៏សព្វគ្រប់ គណៈកម្មការបានសំរេចចិត្តថា មិនចាំបាច់ពិនិត្យព្រំប្រទល់ដែនជាថ្មីឡើងវិញឡើយ ។ គណៈកម្មការមានជាពិសេសនូវអ្នកដំណាងខ្មែរ-ថៃ និងបារាំងជាសមាជិក ។

# ៤- ប្រវត្តិរឿងវិវាទនៃព្រះវិហារ

នៅខាងដើម មានចង្អុលប្រាប់ថា អនុសញ្ញាចុះថ្ងៃទី១៣កុម្ភៈ១៩០៤ បានបញ្ជាក់នូវបន្ទាត់ព្រំប្រទល់ដែនរវាងប្រទេសថៃនិងប្រទេសកម្ពុជា ហើយបានព្រាងបង្កើតគណៈកម្មការចំរុះ ទទួលការខាងកំណត់បន្ទាត់ព្រំប្រទល់ដែននេះ ។

បានបញ្ជាក់ជាថ្មីនូវបន្ទាត់ព្រំប្រទល់ដែនហើយ ខាងក្រោយដែលសន្ធិសញ្ញាចុះថ្ងៃទី២៣មិនា១៩០៧ បានប្រគល់ឱ្យមកវិញដល់ប្រទេសបារាំង គឺថាដល់ប្រទេសកម្ពុជា នូវទឹកដីថ្មីទាំងឡាយដែលស្ថិតនៅផ្នែក ខាងជើងនិងផ្នែកខាងលិចប្រទេស ។

ក្នុងតំបន់ព្រះវិហារ បន្ទាត់ព្រំប្រទល់ដែនបានសំរេចរួចហើយតាមអនុសញ្ញាឆ្នាំ១៩០៤ ហើយបានទាំងបញ្ជាក់ក្នុងឱកាសប្រតិបត្តិអនុសញ្ញានោះ ព្រោះតំបន់នេះទៅជាតំបន់ខ្មែររួចហើយជាស្រេច មុនការត្រឡប់ប្រគល់ឱ្យជាថ្មីម្តងទៀតនៅឆ្នាំ១៩០៧នោះ ។

បន្ទាត់ព្រំប្រទល់ដែននេះបានទទួលការបញ្ជាក់បន្ថែមពីសន្ធិសញ្ញាឆ្នាំ១៩០៧ ។ ដ្បិតពិធីការដែលដាក់ភ្ជាប់នឹងសន្ធិសញ្ញានេះបញ្ជាក់ថា ចាប់តាំងពីចំណុចមួយដែលស្ថិតនៅលើជួរភ្នំដងរែក (ហើយចំណុចនេះគឺពិតជាស្ថិតនៅផ្នែកខាងលិចនៃព្រះវិហារនោះ) ព្រំប្រទល់ដែនរលាយចូលជាមួយតម្រាយដែលគណៈកម្មការកំណត់ព្រំប្រទល់ដែនលើកមុនបានអនុម័តហើយ នៅថ្ងៃទី១៩មករា១៩០៧ (គណៈកម្មការនេះបានរួមប្រជុំដោយអនុវត្តន៍អនុសញ្ញា១៩០៤) ។

ដូច្នេះ ដោយអនុលោមតាមអនុសញ្ញាចុះថ្ងៃ១៣កុម្ភៈ១៩០៤ គណៈកម្មការចំរុះទាំងឡាយបានត្រូវគេតាំងឱ្យមានឡើង ដើម្បីសំរេចបន្ទាត់ព្រំប្រទល់ដែនឱ្យបានទៀងទាត់ ។ ប្រការ៣នៃអនុសញ្ញាបានចែងថា ប្រទេសបារាំង និងប្រទេសសៀម ត្រូវតែងតាំងនាយទាហានទាំងឡាយដើម្បីឱ្យធ្វើជាសមាជិកនៃគណៈកម្មការខាងលើនេះ ហើយការងារនៃគណៈកម្មការនឹងត្រូវប្រព្រឹត្តទៅតែចំពោះព្រំប្រទល់ដែនដែលបានសំរេចហើយក្នុងប្រការ១ ប្រការ២ នៃសន្ធិសញ្ញាព្រមទាំងប្រព្រឹត្តទៅចំពោះតែលើតំបន់ដែលមាននៅជាចន្លោះទន្លេសាបនិងសមុទ្រ ។

គណៈកម្មការចំរុះត្រូវទទួលការតែងតាំងនិងត្រូវចាប់ផ្តើមធ្វើការងាររបស់ខ្លួន ក្នុងរយៈពេល៤ខែ ចាប់ពីមានការឱ្យបច្ចាប័ន្នលើអនុសញ្ញា១៩០៤មក ។




***ព្រំដែនខ្មែរ-សៀមនៅតំបន់ព្រះវិហារ(អនុសញ្ញា១៩០៤)***

គណៈកម្មការនេះបានតាំងនៅជាច្រើនឆ្នាំ ហើយបានបើកពេលប្រជុំជាច្រើនលើក ។ នាយទាហានទាំងឡាយខាងភូមិសាស្ត្របានបំពេញការងារនៃគណៈកម្មការ ។ គឺនាយទាហាខាងភូមិសាស្ត្រនេះហើយដែលបានធ្វើការពិនិត្យជាចាំបាច់គ្រប់យ៉ាងដល់ទីកន្លែង ។

ការងារទាំងឡាយនៃគណៈកម្មការនិងសេចក្តីសំរេចរបស់ខ្លួនមានពោលដោយសង្ខេបក្នុងសេចក្តីកត់ហេតុទាំងឡាយ ជាអាទិក្នុងសេចក្តីកត់ហេតុចុះថ្ងៃទី២ធ្នូ១៩០៦ ចុះថ្ងៃទី៣មករា១៩០៧ ចុះថ្ងៃទី១៨ និងទី១៩មករា១៩០៧ ចុះថ្ងៃទី២តុលា១៩០៧ ។

មានចង្អុលប្រាប់ក្នុងសេចក្តីកត់ហេតុទាំងនោះថា ក្នុងតំបន់ភ្នំដងរែក បន្ទាត់ព្រំប្រទល់ដែនរលាយចូលជាមួយបន្ទាត់បែងចែកទឹក ។

គណៈកម្មការដែលបានរួមប្រជុំដើម្បីអនុវត្តន៍សន្ធិសញ្ញាឆ្នាំ១៩០៧ (ពេលប្រជុំចុងក្រោយបង្អស់ នៅថ្ងៃទី៦មិថុនា១៩០៨) បានចែងថាការបោះគោលបានធ្វើរួចហើយសំរាប់ព្រំប្រទល់ដែនទាំងអស់ រវាងឥណ្ឌូចិន និងប្រទេសសៀម ។

មានសេចក្តីបញ្ជាក់ជាពិសេសថា គោលសញ្ញាព្រំប្រទល់ដែនជាស៊ីម៉ង់ ជាដែកឬជាឈើ មានតាំងនៅត្រង់ចំណុចធំៗខ្លះនៃព្រំប្រទល់ដែន ។

បញ្ជីរាយនាមដែលមានដាក់ភ្ជាប់មកនឹងសេចក្តីកត់ហេតុចុះថ្ងៃទី៦មិថុនា១៩០៨ ពោលរាប់ចំណុចទាំងនោះប៉ុន្តែឥតមានឃើញរាប់ព្រះវិហារផងឡើយ ។ មិនតែប៉ុណ្ណោះសោត កាលៈទេសៈដែលគួរឱ្យស្តាយនេះបានទាំងធ្វើឱ្យឃើញថា ការដាំគោលឥតមានបានធ្វើក្នុងតំបន់នោះឡើយ ។

ម្យ៉ាងទៀត គណៈកម្មការបានទាំងព្រាងធ្វើផែនទីមួយដែលមានព្រំប្រទល់ដែនទាំងអស់រវាងឥណ្ឌូចិននិងប្រទេស

សៀម ដោយប្រើឯកសារការងារខាងធ្វើផែនទី ការត្រាយផ្លូវថ្នល់ ពត៌មានផ្សេងៗទាំងអស់ ។

ផែនទីត្រូវតែបញ្ជាក់ឱ្យឃើញដោយគំនូសនូវសេចក្តីសំរេចចិត្តនៃគណៈកម្មការចំរុះ ដោយចុះក្នុងបញ្ជីយ៉ាងដ៏ត្រឹមត្រូវ នូវការកំណត់ព្រំប្រទល់ដែននៃផែនទី ។

ឯកសារទាំងឡាយខាងធ្វើផែនទី បានត្រូវគេស្ថាបនាដ៏ពិតប្រាកដតាមការធ្វើបន្តគ្នាជាលំដាប់ចំពោះកិច្ចព្រមព្រៀងស្តីពីកំណត់ព្រំប្រទល់ដែន ។ ឯកសារនេះមានប្រាំសន្លឹក ១/២០០.០០០ ដែលមានដាក់សារបានថា **"ផែនទីនៃគណៈកម្មការកំណត់ព្រំប្រទល់ដែនរវាងឥណ្ឌូចិននិងប្រទេសសៀម"** ។ ផែនទីនេះបានស្ថាបនាឡើងជាពីរពេល ៖

**១-** ផែនទីលើកដំបូង បានស្ថាបនាឡើងដោយអនុវត្តន៍អនុសញ្ញាចុះថ្ងៃទី១៣កុម្ភៈ១៩០៤ ហើយដែលស្ថិតនៅក្រោមការដឹកនាំនៃលោក **លីយ៉ុតិណង់កូឡូណែលប៊ែរណា** ។ ផែនទីនេះមានព្រំប្រទល់ដែនថ្មីទាំងអស់ ពីសមុទ្រទៅទន្លេមេកុង ដោយអនុលោមតាមពិពណ៌នា នៅក្នុងប្រការ១-២ និង៣ នៃអនុសញ្ញានោះ ។

**២-** ផែនទីទីពីរ បានត្រូវគណៈបេសកកម្មម៉ុងហ្គ័រ (Mission montguers) ជាអ្នកស្ថាបនាឡើង តាមសន្ធិសញ្ញាចុះថ្ងៃទី២៣មិនា១៩០៧ ហើយក្នុងសន្ធិសញ្ញានេះ ប្រទេសសៀមបានប្រគល់ដល់ប្រទេសបារាំង នូវទឹកដីដ៏សំខាន់ៗជាច្រើនដែលនៅផ្នែកខាងលិចនៃប្រទេសកម្ពុជា ។ ផែនទីទី២នេះ ទៅចប់ត្រឹមជួរភ្នំដងរែកត្រង់ចំណុចដែលតម្រាយថ្មី (នៅឆ្នាំ១៩០៧) យកតាមព្រំប្រទល់ដែនចាស់(នៅឆ្នាំ១៩០៤) រហូតដល់ទន្លេមេកុង ឥតមានកែប្រែអ្វីឡើយ ។

# អំពីព្រះវិហារ

សន្ធិសញ្ញា១៩០៧ មិនបានធ្វើសេចក្តីកែប្រែអ្វីមួយចំពោះទីកន្លែងនោះទេ គឺថាត្រូវស្ថិតនៅដដែលតាមសេចក្តីសំរេចនៃអនុសញ្ញា១៩០៤ ។ ដូច្នេះ ត្រូវរិះរកទីកន្លែងព្រះវិហារនេះក្នុងឯកសារទី១ ដូចបានពោលខាងលើ ហើយជាពិសេសត្រូវមើលក្នុងសន្លឹក ១/២០០.០០០ ដែលមានដាក់សារបានថា **"ដងរែក"** (មានដាក់ជាប់មកនេះ) ។

ឯការពិនិត្យសន្លឹកនេះ បង្ហាញភស្តុតាងយ៉ាងជាក់ច្បាស់ថា តំបន់ព្រះវិហារស្ថិតនៅក្នុងដែនដីខ្មែរ ។

ម្យ៉ាងទៀត **មានផែនទីសៀមមួយ ១/២០០.០០០ ដែលក្រុមភូមិសាស្ត្រសៀមបានស្ថាបនាឡើង** ។ ពិតមែនតែផែនទីនោះធ្វើដោយសង្ខេប ក៏សន្លឹកលេខ៤៤នៃផែនទីនោះ ដែលស្តីពីព្រំប្រទល់ដែននៅដងរែក **ចុះនិទ្ទេសដ៏ពិតប្រាកដថា ទីកន្លែងប្រាសាទព្រះវិហារ ស្ថិតនៅឰដ៏ខាងក្នុងដែនដីខ្មែរ** ។

ផែនទីសៀមនេះ ដែលផ្សាយមកពីក្រុមការងារនៃគណៈកម្មការខាងកំណត់ព្រំដែន បង្ហាញភ័ស្តុតាងឱ្យឃើញថា រាជការសៀមបានទទួលស្គាល់ជាផ្លូវការនូវដំបន់ព្រះវិហារ ថាជាដំបន់មានលក្ខណៈជាខ្មែរ ។ ផ្នែកទាំងពីរនៃផែនទីបារាំង និងផែនទីសៀមពិតជាមានសភាពមិនស្របគ្នាទេ ប៉ុន្តែបង្ហាញឱ្យឃើញថា មានការប្រហាក់ប្រហែលគ្នាជាច្រើន ។ ព្រោះប្រាសាទព្រះវិហារមានកំណត់យ៉ាងជាក់ច្បាស់ក្នុងផែនទីទាំងពីរនោះ ។

**ព្រំប្រទល់ដែននៅជាខាងជើងដាច់ណាត់ពីប្រាសាទព្រះវិហារ ចម្ងាយប្រហែល៥០០ម៉ែត្រ ។ ការប្រហែលគ្នានៃឯកសារទាំងពីរខាងលើបញ្ជាក់ឱ្យឃើញដ៏ពិតប្រាកដថា គូរទាំងសងខាង(សៀមនិងបារាំង)បានព្រមព្រៀងជាមួយគ្នាទុក**

**ព្រះវិហាឱ្យស្ថិតនៅដែនដីខ្មែរ ។**

សូមជំរាបថា ផែនទីនៃសន្យានុភាព ១/១០០.០០០ ដែលជាការស្ថាបនារបស់អាជីវកម្មខាងថតរូប ខាងអាកាស ១/៥០.០០០ នឹងជាការស្ថាបនានៃការពង្រីកផែនទី ១/២០០.០០០ របស់គណៈកម្មការខាងកំណត់ព្រំដែន កំណត់តម្រាយព្រំដែនតាមដំណើរដែលថាប្រាសាទព្រះវិហារស្ថិតនៅក្នុងដែនដីខ្មែរនោះ ។



*ប្រាសាទព្រះវិហារគោប៉ូរៈទី២*

**ជាទីបំផុត ដើម្បីបញ្ជាក់ការពិនិត្យខាងផែនទីនេះ គេសូមរំលឹកឱ្យដឹងថា ផែនទី *ប៉ូរម៉ាម៉ាឡាយអំផែឥណ្ឌូស្ដីណា* ដែលក្រុម "ថេហ្សេអូប្រ្កាហ្វីកាល់អាំងស្ទីទុតអេឌីនប៊ូក១៩៥៣" បានបោះពុម្ពផ្សាយ នៅចក្រភពអង់គ្លេស បង្ហាញឱ្យឃើញយ៉ាងជាក់ច្បាស់ថា ព្រះវិហារនៅក្នុងដែនដីខ្មែរ ។**

**សូមជំរាបជាអវសានថា តាមសេចក្ដីប្រកាសច្រើនលើក ជាផ្លូវការ រដ្ឋាភិបាលថៃក៏បានប្រកាសយ៉ាងជាក់ច្បាស់ថា ប្រាសាទព្រះវិហារស្ថិតនៅក្នុងដែនដីខ្មែរដែរ ។**

**ក)- នៅថ្ងៃទី១៤មករា១៩៥៤** រដ្ឋាភិបាលប្រទេសថៃ បានឆ្លើយតបតាមលក្ខខ័ណ្ឌដូចតទៅ ចំពោះអ្នកសួរដេញដោលផ្សេងៗដែលជាសមាជិកនៃរដ្ឋសភា ។

ដំណាងរាស្ត្រជាអ្នកសួរដេញដោលទាំងឡាយបានដណ្ដឹងសួរថា តើការដែលប្រទេសថៃទទួលស្គាល់ប្រទេសកម្ពុជា តំរូវឱ្យប្រទេសថៃឈប់ក្ដួចកាន់ជាស្ថាពរនូវសិទ្ធិរបស់ខ្លួនលើខេត្តទាំងឡាយដែលត្រឡប់ប្រគល់ឱ្យជាថ្មីម្ដងទៀតនៅឆ្នាំ១៩៤៧ឬ ។

ព្រះអង្គម្ចាស់អធិប ជារដ្ឋមន្ត្រីក្រសួងការបរទេសថៃ បានមានព្រះបន្ទូលបញ្ជាក់ថា ទ្រង់គិតដល់តម្លៃឯករាជ្យនៃប្រទេសកម្ពុជា ជាងការបានខេត្តទាំងឡាយដែលត្រូវប្រគល់ឱ្យទៅប្រទេសកម្ពុជាវិញនៅឆ្នាំ១៩៤៦ទៅទៀត ។ ទ្រង់បានមានព្រះបន្ទូលថែមទៀតថា រដ្ឋាភិបាលថៃមិនប្រព្រឹត្តនយោបាយពង្រីកដែនដីទេ ហើយប្រទេសថៃមានសេចក្ដីពេញចិត្ត

ដោយឃើញមានការកែតម្រូវព្រំប្រទល់ដែនខ្លះ ដែលមានប្រយោជន៍បន្តិចបន្តួច ដូចជាបញ្ហាភ្នំខាវ-ព្រះវិហារ ។ រដ្ឋាភិបាលថៃពេញចិត្តតាមចំណុចទាំងនោះ ក្នុងកិច្ចចរចាសំរុះសំរួលជាមួយប្រទេសកម្ពុជា ដោយអនុលោមតាមច្បាប់អន្តរជាតិ ។ **ហេតុដូច្នេះ គឺថាប្រទេសថៃទទួលស្គាល់ដ៏ពិតប្រាកដថា ព្រះវិហារជារបស់ប្រទេសកម្ពុជា ។**

**ខ)-** ពីរ-បី ខែក្រោយមក នៅថ្ងៃទី១៣ធ្នូ១៩៥៩ សេនាប្រមុខភីនគុនហាវ៉េ ជារដ្ឋមន្ត្រីទី១ថៃស្តីទី ក្នុងសេចក្តីប្រកាសចំពោះទីភ្នាក់ងារសារពត៌មានបារាំង បានប្រកាសអំពីរឿងបញ្ហាព្រំប្រទល់ដែនថា រដ្ឋាភិបាលថៃមានបំណងនឹងចាត់តាំងគណៈកម្មការមួយដើម្បីកំណត់ព្រំប្រទល់ដែនរវាងប្រទេសថៃ ប្រទេសលាវ និងប្រទេសកម្ពុជា ហើយថាជាពិសេស គួរគប្បីតែដោះស្រាយបញ្ហាភ្នំព្រះវិហារដែលនៅទីនោះ **ព្រះចៅរាជាធិរាជខ្មែរមួយព្រះអង្គ បានទ្រង់កសាងប្រាសាទមួយដែលគេអាចនឹងអញ្ជើញទៅដល់ តែដោយត្រាច់តាមដែនដីថៃនោះ** (សារពត៌មានវៀតណាមលេខ១៧៦៤ចុះថ្ងៃទី១៤ធ្នូ១៩៥៩) ។

**ត្រង់នេះទៀត គឺជាការទទួលស្គាល់ដ៏ពិតប្រាកដថា ព្រះវិហារជារបស់ប្រទេសកម្ពុជាមែនៗ ។**

**គ)-** សៀវភៅថៃមួយមានលក្ខណៈជាផ្លូវការ ហើយដាក់ឈ្មោះថា "**ថៃណែសម័យសាងឆាត**" បោះពុម្ពផ្សាយនៅពុទ្ធសករាជ២៤៨៤ (គ្រឹស្តសករាជ១៩៤១) មានអត្ថបទនៃអនុសញ្ញាក្រុងតូក្យូ ចុះថ្ងៃទី៩ឧសភា១៩៤១ ដែលបានប្រគល់ដល់ប្រទេសថៃ នូវអតីតដែនដីឥណ្ឌូចិនបារាំងមួយចំណែកខាងប្រទេសលាវនិងប្រទេសកម្ពុជា ហើយបញ្ជាក់ដោយមានទាំងរូបថតជាជំនួយផងថា ប្រាសាទព្រះវិហារ និង វត្តផូ (ព្រំប្រទល់ដែនលាវ) បានចូលមកជារបស់ប្រទេសថៃ បន្ទាប់ពីមានការកែប្រែព្រំប្រទល់ដែន តាមអនុសញ្ញានេះ ។

**ត្រង់ទីនេះទៀត គឺទទួលស្គាល់ថា ព្រះវិហារ មុនឆ្នាំ១៩៤១ ពិតជារបស់ខ្មែរ ។**

សន្ធិសញ្ញានាក្រុងវ៉ាស៊ីនតុន ចុះថ្ងៃទី១៧ឧសភា១៩៤៦ ដែលបានស្ថាបនាឡើងវិញ នូវច្បាប់ដើមទាំងអស់ ស្តីអំពីដែនដីទាំងឡាយនៃអតីតឥណ្ឌូចិនបារាំង មិនត្រឹមតែបានទុកអនុសញ្ញា១៩៤១ ជាមោឃៈប៉ុណ្ណោះទេ ឯគណៈកម្មការបង្រួបបង្រួមដែលបានត្រូវគេតាំងឡើងដើម្បីអនុវត្តន៍សន្ធិសញ្ញានេះ ក៏បានទាំងទទួលស្គាល់ទៀតថា មិនបានធ្វើសេចក្តីកែប្រែថ្មីអ្វីមួយខាងព្រំប្រទល់ដែនដែលទាក់ទងទៅនឹងស្ថានការណ៍មុនឆ្នាំ១៩៤១ឡើយ ។ **រាជការនៃប្រទេសថៃបានប្រគល់ឱ្យទៅប្រទេសលាវវិញ នូវប្រាសាទវត្តផូ ប៉ុន្តែឥតមានប្រគល់ប្រាសាទព្រះវិហារដល់ប្រទេសកម្ពុជាឡើយ ។**

ॐ

ॐ ॐ

# ៥- ដើមកំណើតនៃការវិវាទ រវាងប្រទេសកម្ពុជានិងប្រទេសថៃ

ទោះបីមានបទបញ្ញត្តិដ៏យ៉ាងច្បាស់លាស់នៃសន្ធិសញ្ញាទាំងឡាយ ទោះបីមានការបំភ្លឺពីឯកសារខាងធ្វើផែនទីដែលស្ថាបនាឡើងដោយអនុសញ្ញាទាំងនោះ ទោះបីមានសេចក្តីប្រកាសជាផ្លូវការខ្លះនៃរដ្ឋាភិបាលថៃដែលលើកយកមកពោលរំលឹកឱ្យដឹងត្រង់កថាខ័ណ្ឌទី៤ ក្នុងបច្ចុប្បន្នសេចក្តីជូនដំណឹងនេះក៏ដោយ រាជការប្រទេសថៃក៏នៅតែមិនព្រមឈប់ធ្វើបាតុកម្មដោយសញ្ញាផ្សេងៗ ថាខ្លួននៅតែចូលចិត្តទុកប្រាសាទព្រះវិហារជាប្រាសាទតាំងនៅក្នុងដែនដីថៃដដែលទៀត ។

គួរឱ្យធុញទ្រាន់នឹងពោលរៀបរាប់រឿងហេតុទាំងអស់ដែលបញ្ជាក់ឱ្យឃើញពិតប្រាកដនូវឆន្ទៈនៃរាជការប្រទេសថៃ ដើម្បីសំគាល់ថាប្រាសាទព្រះវិហារស្ថិតនៅក្នុងដីថៃនោះជាពន់ពេក ។

សូមពោលរំលឹកតែការប្តូរលិខិតខាងការទូតដ៏ធំៗ ដែលបានកើតមានឡើងក្នុងរឿងនេះ ។

**ក)-** មុនឯករាជ្យប្រទេសកម្ពុជា ស្ថានឯកអគ្គរាជទូតនៃប្រទេសបារាំង ប្រចាំក្រុងបាងកក បានតវ៉ាជាច្រើនលើក ប្រឆាំងនឹងការប្រព្រឹត្តិរាជការថៃ ៖

**១/** លិខិតកត់ហេតុ**លេខ២៩/៤៩/C** ចុះថ្ងៃទី១០កុម្ភៈ១៩៤៩ តវ៉ាប្រឆាំងនឹងហេតុថា រាជការប្រទេសថៃបានបញ្ជូនឆ្មាំម្នាក់ និងកូនគូលី៣នាក់ ឱ្យទៅកាប់ឆ្ការព្រៃចេញពីប្រាសាទព្រះវិហារ ។ គឺលិខិតកត់ហេតុប្រឆាំងនឹងការជិះជាន់ទឹកដីខុសច្បាប់នេះហើយដែលបញ្ជាក់ថា ប្រាសាទព្រះវិហារស្ថិតនៅក្នុងដែនដីខ្មែរទេ ។

**២/** លិខិតកត់ហេតុ**លេខ៦៩/៤៩/C** ចុះថ្ងៃទី២១មិនា១៩៤៩ បញ្ជាក់បន្ថែមលើសេចក្តីតវ៉ាលើកមុន ហើយសុំចំពោះរដ្ឋមន្ត្រីនៃខាងក្រសួងការបរទេស ឱ្យបំបាត់កុំឱ្យមានស្ថានការណ៍ប្រកបដោយសេចក្តីសង្ស័យដែលផ្សាយមកពីការប្រព្រឹត្តិរបស់រដ្ឋាភិបាលលោក ហើយជាពិសេសសុំឱ្យបន្ថយឆ្មាំជាតិថៃទាំងឡាយដែលតាំងនៅក្បែរប្រាសាទនោះចាកចេញ ។

**៣/** កាលពី**ថ្ងៃទី២៨កក្កដា១៩៤៩** តាមលិខិតលេខ១៩៧ លោកឡេអុងម៉ារសាល់ ជាឯកអគ្គរាជទូតនៃប្រទេសបារាំងប្រចាំក្រុងបាងកក បានជូនដំណឹងដល់អ្នកស្នងការជាន់ខ្ពស់នៃប្រទេសបារាំងប្រចាំប្រទេសឥណ្ឌូចិនថា ភ្នាក់ងាររាជការម្នាក់នៃស្ថានឯកអគ្គរាជទូតរបស់លោក បានបង្ហាញផែនទីកំណត់ព្រំប្រទល់ដែន ១/២០០.០០០ ចំពោះអគ្គនាយកនៃមន្ទីរខាងបូព៌ាទិស នៅមន្ទីររដ្ឋមន្ត្រីថៃខាងក្រសួងការបរទេស ។ ភ្នាក់ងាររាជការនេះដែលទទួលស្គាល់ទុកការតវ៉ាទាមទារនៃប្រទេសកម្ពុជាថាជាមានសភាពដ៏ត្រឹមត្រូវនោះ បានបញ្ជាក់ថាផែនទីទាំងឡាយដែលបានផ្ញើមក បានត្រូវគេដាក់ឱ្យគណៈរដ្ឋមន្ត្រីពិនិត្យហើយ ហើយថាស្ថានឯកអគ្គរាជទូតនៃប្រទេសបារាំងនឹងបាននូវសេចក្តីពេញចិត្តក្នុងពេលក្រោយជាមិនខាន ។ ឯចម្លើយដែលបានផ្សាយចេញនេះ មិនដែលឃើញបានមកដល់ស្ថានឯកអគ្គរាជទូតនៃប្រទេសបារាំងសោះ ។

**៤/** លិខិតកត់ហេតុ**លេខ១១៨០** ចុះថ្ងៃទី៣កក្កដា១៩៥០ នៃស្ថានឯកអគ្គរាជទូតប្រទេសបារាំង ប្រចាំបាងកក បានផ្ញើជូនទៅរដ្ឋាភិបាលថៃ ដើម្បីរំលឹកអំពីលិខិតដែលខ្លួនបានផ្ញើទៅក្នុងពេលមុន ។

**ខ-** លិខិតទាំងឡាយអំពីរឿងប្រាសាទព្រះវិហារ បានត្រូវគេផ្ញើប្តូរគ្នាទៅវិញទៅមកជាថ្មីនៅពេលក្រោយឯករាជ្យនៃប្រទេសកម្ពុជា រវាងស្ថានឯកអគ្គរាជទូតខ្មែរដែលទើបនឹងតាំងថ្មីនៅនាក្រុងបាងកក និងរដ្ឋាភិបាលប្រទេសថៃ ។

លទ្ធផលជាវិជ្ជមានឥតបានកើតមានបន្តិចសោះឡើយ ។

ការប្រព្រឹត្តិនៃរាជការប្រទេសថៃនៅតែដដែល រដ្ឋាភិបាលខ្មែរក៏ត្រូវតែធ្វើសេចក្តីតវ៉ាដូចគ្នានឹងសេចក្តីតវ៉ាដែលអ្នកដំណាងទាំងឡាយនៃរដ្ឋាភិបាលបារាំងបានផ្ញើជូនទៅរដ្ឋាភិបាលថៃនោះដែរ ។

**១.-** ដូច្នេះ តាមលិខិត**លេខ១៤-DGP-X** ចុះថ្ងៃទី២២មករា១៩៥៤ ឯកអគ្គរាជទូតនៃប្រទេសកម្ពុជាប្រចាំក្រុងបាងកក បានតវ៉ាចំពោះរដ្ឋមន្ត្រីក្រសួងការបរទេសថៃ ប្រឆាំងនឹងសេចក្តីបង្គាប់ដែលរាជការខេត្តម៉មរាន(ប្រទេសថៃ) គឺថារាជការខេត្តនេះបានបង្គាប់ឱ្យគូលីខ្មែរ៣នាក់ដែលរាជការខ្មែរបានជ្រើសយកមកឱ្យនៅថែរក្សាប្រាសាទនោះឱ្យឈប់បំពេញមុខការរបស់ខ្លួន និងឱ្យថយចេញពីទីនោះផង ។

**២.-** តាមលិខិតកត់ហេតុធ្វើ (ឃ្លានេះរលប់បាត់ពីសំណៅដើម) **១៩៥៤** ដែលជាចម្លើយទី១របស់រដ្ឋាភិបាលថៃក្នុងរឿងនេះរដ្ឋមន្ត្រីថៃក្រសួងការបរទេសបានប្រាប់ថាបានទទួលលិខិតនៃគណៈបេសកកម្មខាងការទូតរបស់យើងហើយដោយបញ្ជាក់ថា លោកនឹងពិនិត្យលិខិតនេះដោយការយកចិត្តទុកដាក់ ។



*ប្រាសាទព្រះវិហារគោប៉ូរៈទី៣*

**៣.-** កាលពី**ថ្ងៃទី១៣មិនា១៩៩៤** ឯកអគ្គរាជទូតនៃប្រទេសកម្ពុជា បានជួបជាមួយអនុរដ្ឋលេខាធិការក្រសួងការបរទេសនៃរដ្ឋាភិបាលថៃ ហើយលោកនេះបានប្រាប់ថា បញ្ហាព្រះវិហារត្រូវឱ្យរដ្ឋាភិបាលលោកពិនិត្យដោយហ្មត់ចត់ ហើយថា លោកមុខនឹងធ្វើជូនឱ្យត្រឹមត្រូវតាមពាក្យសុំនៃរដ្ឋាភិបាលខ្មែរ ។

ប៉ុន្តែរាជការប្រទេសថៃ នៅតែឱ្យទាហានថៃមើលថែរក្សាប្រាសាទព្រះវិហារនោះតទៅទៀតដដែល ។

**៤.-** នៅ**ថ្ងៃទី៩មិថុនា១៩៩៤** លោកឯកអគ្គរាជទូតនៃប្រទេសកម្ពុជាប្រចាំបាងកក បានផ្ញើលិខិតថ្មីមួយ ទៅមន្ទីររដ្ឋមន្ត្រីក្រសួងការបរទេសថៃ សុំឱ្យធ្វើអន្តរាគមន៍ចំពោះរាជការមានសមត្ថភាពនៃប្រទេសរបស់ខ្លួន ដើម្បីឱ្យទាហានថយចេញពីតំបន់ព្រះវិហារ ដែលខ្លួនបានកាន់កាប់នោះ ។

ទោះបីធ្វើសំណើរគិតគូរយ៉ាងដូចម្តេចក៏ដោយ ក៏ឥតបានលទ្ធផលអ្វីឡើយ រដ្ឋាភិបាលខ្មែរបានពោលរំលឹករឿងខាងលើនេះជាញឹកញយ ហេតុទាំងនេះហើយដែលបង្ហាញឱ្យឃើញថា រដ្ឋាភិបាលខ្មែរមិនមែនបណ្តោយទុករឿងនេះឱ្យសាបរលាយឡើយ ព្រមទាំងបណ្តាលឱ្យឃើញការយកចិត្តទុកដាក់ជាខ្លាំងនៃរដ្ឋាភិបាលខ្មែរចំពោះបញ្ហានេះ ។

ទោះបីមានការគិតគូជាញឹកញយឥតលំហែ ដូចបានពោលខាងនេះក៏ដោយ រដ្ឋាភិបាលប្រទេសថៃ ក៏នៅតែរឹងទទឹងរក្សាទុកនូវទាហានទាំងឡាយនៅទីកន្លែងនោះ ឱ្យជាអ្នកថែរក្សានិងអនុរក្សប្រាសាទព្រះវិហារ ដែលជាព្រះប្រាសាទស្ថិតនៅក្នុងដីខ្មែរនោះ ។

បាតុកម្មខាងការជិះជាន់របស់រាជការប្រទេសថៃឥតបានឈប់ម្តងសោះ ហើយបានធ្វើឱ្យឃើញជាទម្រង់ផ្សេងៗ ។

**៥.-** ដូច្នេះព្រះរាជរដ្ឋាភិបាលបានដឹង ៖

- ▸▸ នៅក្នុង**ខែមករា១៩៩៥** ថារាជការប្រទេសថៃបានយកផ្ទាំងមួយ ចារិកជាអក្សរខ្មែរនិងអក្សរថៃទៅបោះនៅឯព្រះវិហារ ហាមឃាត់ជនបរទេសទាំងអស់ មិនឱ្យត្រាច់ទៅតាមប្រាសាទនេះ ។
- ▸▸ នៅក្នុង**ខែកុម្ភៈ១៩៩៥** ថាមានឆ្នាំជាតិថៃម្នាក់ បានចុះក្នុងបញ្ជីមួយ ដើម្បីជាប្រយោជន៍រាជការប្រទេសថៃ នូវនាម គុណសម្បត្តិនិងអាសយដ្ឋាននៃអ្នកទស្សនាចរណ៍ទាំងឡាយ ។

**៦.-** ទោះបីមានការគិតគូជាច្រើនដូចបានពោលខាងលើនេះ មានការកែតម្រូវ មានការតវ៉ាពីរដ្ឋាភិបាលខ្មែរនិងពីអ្នកដំណាងរបស់ខ្លួនប្រចាំក្រុងបាងកកក៏ដោយ រាជការប្រទេសថៃក៏នៅតែព្យាយាមប្រកាន់អាកប្បកិរិយារឹងរូសរបស់ខ្លួនដដែល ។ ដូចជាក្នុងពេលថ្មីៗនេះ រាជការខ្មែរបានសង្កេតឃើញថា ៖

**ក)** មានកងល្បាតនៃតម្រួតថៃបាននៅអនុរក្សនិងត្រួតពិនិត្យប្រាសាទនោះជាអចិន្ត្រៃយ៍ ។

**ខ)** មានទង់ជាតិថៃបានបក់រវេចនៅពីខាងមុខប្រាសាទ នៅត្រង់មាត់ខ្លង់រាបផ្នែកខាងខ្មែរ ។ អំពីរឿងនេះគេសង្កេតឃើញថា រាជការប្រទេសថៃជួនកាលបង្ហូតទង់ជាតិនៅឯព្រះវិហារ ជួនកាលទំលាក់ចុះមកវិញ តាមចិត្តដែលខ្លួនប្រាថ្នា ចង់សំដែងឱ្យច្បាស់នូវគំនិតខាងសំរុះសំរួល ឬក៏នូវគំនិតខាងការតវ៉ាទាមទារ ។

**គ)** រាល់ថ្ងៃក្រុមតម្រួតមួយកង ដែលតាំងនៅចម្ងាយប្រហែល២០០ម៉ែត្រ ជាខាងជើងច្រកចូល គឺថានៅក្នុងប្រទេសថៃ បានបញ្ជូនពួកយាមល្បាតឱ្យទៅឯព្រះវិហារ ។ ការត្រិះរិះអំពីទង់ជាតិ ចំពោះរឿងនេះ ក៏មានសភាពដូចគ្នាដែរ ។ មានពេលខ្លះ រាជការប្រទេសថៃដកទាហាននិងតម្រួតចេញ មានពេលខ្លះទៀត ថែរក្សាពួកនេះទុកឱ្យនៅនឹង

កន្លែង ។

**ឃ)** មានក្រុមតម្រួតប្រកបដោយអាវុធប្រហែល១០០នាក់ ដែលសំចតនៅចម្ងាយ៨គីឡូម៉ែត្រពីព្រះវិហារ សំរាប់ផ្លាស់ប្តូរក្រុមតម្រួតក្នុងរយៈពេល១៥ថ្ងៃ ។

**ង)** នៅតាមផ្លូវលំមកពីឫស្សី ចម្ងាយប្រហែល៥០០ម៉ែត្រខាងមុខទ្វារចូលទៅក្នុងប្រាសាទ មានចារិកជាអក្សរថៃលាបថ្នាំស នៅត្រង់ស្នាប់ជើងនៃសរសេរ ឬនៅត្រង់ទ្រនាប់ជើងរូប ។ ពួកខ្មែរដែលត្រូវការទៅហួសពីប្រាសាទនេះត្រូវសុំសេចក្តីអនុញ្ញាតពីតម្រួតថៃ ។ ដូច្នេះ រាជការនៃប្រទេសថៃបានកំណត់កន្លែងព្រំប្រទល់ដែនតែម្នាក់ឯង ហើយអនុរក្សព្រំប្រទល់ដែននេះទុកជាយ៉ាងម៉ឺងម៉ាត់ ។

**ច)** មានអ្នកទេសចរណ៍ ឬឥស្សរជនជនជាច្រើនមកទស្សនាប្រាសាទព្រះវិហារជាញឹកញយ តាមឧទ្ធម្ភាគចក្រក៏មាន តាមរថយន្តក៏មាន ។

**ឆ)** ក្នុងខែកញ្ញា១៩៥៦ រាជការប្រទេសថៃបានតម្រូវចំពោះអ្នកស្រុកក្នុងភូមិខ្មែរមួយ ដែលនៅជិតទីនោះ (ភូមិឫស្សី) ឱ្យធ្វើជាគូលីជួសជុលថ្នល់ដែលមកពីណាមឱមក្នុងដែនដីថៃ ។

រដ្ឋាភិបាលខ្មែរក៏បានគឹតនឹងឱ្យមនុស្សទៅកាន់កាប់តំបន់ព្រះវិហារ ដើម្បីញុំាងសិទ្ធិដ៏ពិតប្រាកដរបស់ខ្លួនឱ្យមានរូបរាងឡើងដែរ កាលដែលខ្លួនបានទទួលកាន់កាប់អំណាចនៃប្រទេសបន្តពីរាជការបារាំងមកនោះ ។ ម៉្យាងទៀត ពេលក្រោយឯករាជ្យ រដ្ឋាភិបាលខ្មែរក៏បានចាត់ចែងរឿងនេះមួយរំពេច ប៉ុន្តែដោយហេតុមានការពិបាកនឹងចូលទៅដល់តំបន់នោះ រដ្ឋាភិបាលខ្មែរក៏ត្រូវតែឈប់បង្អង់សិន ។ ប៉ុន្តែក្នុងប៉ុន្មានពេលក្រោយមក ដោយអាកប្បកិរិយានៃរាជការថៃបានធ្វើឱ្យមានការរំភើបនោះ រដ្ឋាភិបាលខ្មែរក៏បានគិតថា នឹងទៅកាន់កាប់កន្លែងនោះជាថ្មីម្តងទៀត ។ ប៉ុន្តែរដ្ឋាភិបាលខ្មែរទៅជាមិនបានទៅកាន់កាប់វិញព្រោះរាជការប្រទេសថៃបានទៅកាន់កាប់មុនខ្លួនរួចទៅហើយ ។ **គឺដើម្បីជៀសវាងឧប្បត្តិហេតុខ្លះ ដែលនឹងធ្វើឱ្យខូចការប្រស្រ័យទាក់ទងរវាងប្រទេសទាំងពីរតែប៉ុណ្ណោះ បានជារដ្ឋាភិបាលខ្មែរមិនបានប៉ុនប៉ងឱ្យទៅកាន់កាប់ព្រះវិហារ ហើយពេញចិត្តយករឿងនេះដាក់ធ្វើកិច្ចចរចាទ្វេភាគីវិញ បើកាលណាមិនសំរេច ដូចសេចក្តីប្រាថ្នា នឹងត្រូវធ្វើពាក្យមួយប្តឹងទៅតុលាការអន្តរជាតិ ព្រោះឥឡូវការបរាជ័យកើតមានច្បាស់ហើយ ។**

ដទៃពីការជិះជាន់ដូចបានថ្លែងជូននៅខាងលើនេះ សូមរៀបរាប់ថែមទៀតនូវសៀវភៅនិងការផ្សាយខ្លះ មានកំណើតពីប្រទេសថៃ ដែលឥតកោតញញើតក្នុងការភ្ជាប់តំបន់ព្រះវិហារទៅក្នុងដែនដីថៃនោះ ។

**១-** សេចក្តីរាយការណ៍ប្រចាំឆ្នាំក្នុងព.ស.២៤៩៧ នៃមន្ទីររដ្ឋមន្ត្រីថៃ ខាងក្រសួងគមនាគមន៍ មួយអន្លើ និងផែនទីមួយនៃប្រទេសថៃ បានចុះនិទ្ទេសបញ្ចូលព្រះវិហារទៅក្នុងផែនទីថៃ ។

**២-** ការផ្សាយឈ្មោះ "ខាវព្រះវិហារ" (ភ្នំព្រះវិហារ) ផ្សាយចេញពីការិយាល័យវប្បធម៌វិចិត្រសិល្បៈ ដែលនៅក្នុងឱវាទវិជ្ជាស្ថានជាតិខាងវប្បធម៌ ។ ក្នុងសេចក្តីបញ្ចប់ ការផ្សាយនោះចង្អុលប្រាប់ថា *"នៅកំពូលខ្ពង់រាប ទង់ជាតិថៃបក់រវិកដោយខ្យល់ ។ ហើយរឿងនេះ បង្ហាញឱ្យឃើញដល់យើងជាជាតិថៃ នូវមនោសញ្ចេតនាប្រកបដោយសេចក្តីរីករាយឥតឧបមា និងប្រកបដោយសន្តិសុខ កាលណាបានឃើញទង់ជាតិយើងបក់នៅលើកំពូលភ្នំ ដែលស្ថិតនៅពីលើព្រំប្រទល់ដែននៃប្រទេសដទៃមួយ"* ។

# ៦- សភាពនៃវិវាទថ្មីៗ (មកទល់ឆ្នាំ១៩៥៨?)

កាលពីថ្ងៃទី១២មេសា១៩៥៦ ឯកអគ្គរាជទូតនៃប្រទេសថៃប្រចាំប្រទេសកម្ពុជា បានប្រគល់ដល់មន្ទីររដ្ឋមន្ត្រីខ្មែរខាងក្រសួងការបរទេស នូវជំនួយសរណាមួយ មានការជូនយោបល់ដែលរដ្ឋាភិបាលប្រទេសថៃថ្លែងចំពោះរដ្ឋាភិបាលប្រទេសកម្ពុជា ដើម្បីសំរុះសំរួលបញ្ហាទាំងឡាយនៅមិនទាន់ដាច់ស្រេច រវាងគូទាំងសងខាង ជាប្រយោជន៍ទៅវិញទៅមកនៃប្រទេសទាំងពីរ ។

រដ្ឋាភិបាលនៃប្រទេសកម្ពុជាបានចូលចិត្តថា ការជូនយោបល់នៃជំនួយសរណានេះ មានសភាពដ៏ត្រឹមត្រូវ និងប្រកបដោយប្រយោជន៍ ហើយក៏បានឆ្លើយតបដោយពេញចិត្ត តម្រូវតាមជំនួយសរណានេះ ។ ក្នុងរឿងស្តីពីបញ្ហាព្រំព្រទល់ដែន ហើយជាអាទិ៍ក្នុងរឿងស្តីពីព្រះវិហារ ចម្លើយនៃរដ្ឋាភិបាលប្រទេសកម្ពុជា មានសេចក្តីដូចតទៅ ៖

*"ព្រះរាជរដ្ឋាភិបាលប្រទេសកម្ពុជា កំណត់ហេតុចំពោះរឿងដែលថា ព្រះរាជរដ្ឋាភិបាលនៃប្រទេសថៃ បានប្រុងប្រៀបនឹងពិភាក្សាបញ្ហាព្រំប្រទល់ដែនទាំងអស់ ដោយអនុលោមតាមគោលច្បាប់អន្តរជាតិនិងគោលច្បាប់ខាងយុត្តិធម៌ ។ ចំពោះរឿងនេះ ព្រះរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាបានសូមរំលឹកឱ្យដឹងថា មានសន្ធិសញ្ញានិងកិច្ចព្រមព្រៀងជាច្រើនដែលប្រទេសបារាំងបានចុះហត្ថលេខា ហើយក្នុងនាមនៃប្រទេសកម្ពុជា ហើយប្រទេសថៃក៏បានចុះហត្ថលេខាដែរ ជាពិសេសគឺសន្ធិសញ្ញាចុះថ្ងៃទី២៣មិនា១៩០៧ និងពិធីការដាក់ភ្ជាប់មកជាមួយព្រមទាំងកិច្ចព្រមព្រៀងនាក្រុងវ៉ាស៊ីនតុនចុះថ្ងៃទី១៧វិច្ឆិកា១៩៤៦ ដែលកំណត់ព្រំប្រទល់ដែនរវាងប្រទេសទាំងពីរនោះ ។ ដោយបានទទួលកាន់កាប់រាជការបន្តពីប្រទេសបារាំង បន្ទាប់ពីមានកិច្ចព្រមព្រៀងស្តីពីឯករាជ្យនៃប្រទេសកម្ពុជានោះ ព្រះរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជាបានពឹងផ្អែកទៅលើសន្ធិសញ្ញានិងកិច្ចព្រមព្រៀងអន្តរជាតិទាំងឡាយដែលប្រទេសបារាំងបានចុះហត្ថលេខាក្នុងនាមរបស់ខ្លួន ។ ហេតុដូច្នេះ ព្រះរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា ព្រមទទួលរបៀបធ្វើកិច្ចពិភាក្សានូវបញ្ហាព្រំប្រទល់ដែនហើយជាអាទិ៍គឺស្តីពីកំណត់ព្រំប្រទល់ដែនដីយ៉ាងជាក់លាក់តាមមូលដ្ឋាននៃសន្ធិសញ្ញានិងកិច្ចព្រមព្រៀងទាំងឡាយដែលកន្លងទៅហើយនោះ" ។*

រដ្ឋាភិបាលនៃប្រទេសថៃ ក៏បាននៅស្ងៀមចំពោះចំណុចយោបល់ដែលរដ្ឋាភិបាលនៃប្រទេសកម្ពុជា បានថ្លែងជូនដូចខាងលើនេះ ។ តាមលិខិតចុះថ្ងៃទី៨មេសា១៩៥៧ ផ្ញើជូនទៅរដ្ឋមន្ត្រីក្រសួងការបរទេសនៃរដ្ឋាភិបាលថៃ ឯកអគ្គរាជទូតនៃប្រទេសកម្ពុជាប្រចាំក្រុងបាងកក បានយល់ថា ត្រូវតែបញ្ជាក់បន្ថែមលើចំណុចយោបល់នៃរដ្ឋាភិបាលរបស់ខ្លួនស្តីអំពីបញ្ហានេះ ហើយក៏បានថ្លែងជាថ្មីនូវបំណងថាប្រទេសថៃមុខជានឹងបញ្ជាក់បន្ថែមមិនខានថា ប្រាសាទព្រះវិហារជារបស់ប្រទេសកម្ពុជា ដោយអាងដល់កិច្ចព្រមព្រៀងបារាំង-សៀម ចុះថ្ងៃទី១៧ឧសភា១៩៤៦ ហើយម្យ៉ាងទៀតថា[ប្រទេសថៃ]មុខជានឹងព្រមទទួលតាមគោលការណ៍ដែលរដ្ឋាភិបាលនៃប្រទេសកម្ពុជាបានស្នើសុំឱ្យពិនិត្យបញ្ហាព្រំប្រទល់ដែន ហើយជាអាទិ៍គឺស្តីពីកំណត់ព្រំប្រទល់ដែនយ៉ាងជាក់លាក់ តាមមូលដ្ឋាននៃសន្ធិសញ្ញានិងកិច្ចព្រមព្រៀងទាំងឡាយដែលកន្លងទៅហើយ ។

ជាទីបំផុត នៅ**ថ្ងៃទី១១ឧសភា១៩៥៧** រដ្ឋាភិបាលប្រទេសថៃបានព្រមទទួលរបៀបធ្វើកិច្ចពិភាក្សាអំពីបញ្ហាព្រំប្រ

ទល់ដែនរវាងប្រទេសទាំងពីរ ហើយបានស្នើសុំតាំងគណៈកម្មការចំរុះមួយ សំរាប់កំណត់ព្រំប្រទល់ដែននេះ ។

ប៉ុន្តែ ចម្លើយនេះមិនធ្វើឱ្យជាទីពេញចិត្តដល់រដ្ឋាភិបាលប្រទេសកម្ពុជាឡើយ ព្រោះចម្លើយភ្លេចបញ្ជាក់ថាកិច្ចពិភាក្សានេះនឹងអាចប្រព្រឹត្តិទៅតាមតែមូលដ្ឋាននៃសន្ធិសញ្ញា និងកិច្ចព្រមព្រៀងទាំងឡាយ ជាធរមាន ដែលជាសារវន្តដល់ប្រទេសកម្ពុជា ។

ដូច្នេះ ប្រទេសកម្ពុជា នឹងព្រមទទួលរបៀបនៃគណៈកម្មការចំរុះបាន លុះណាតែគណៈកម្មការនេះ ត្រូវបំពេញមុខងាររបស់ខ្លួនខាងសំរួលករណីកិច្ចវិវាទ ស្តីអំពីកំណត់ព្រំប្រទល់ដែន ដោយមិនដាក់គោល នៃការកំណត់ព្រំប្រទល់ដែន ដូចបានសំរេចរួចមកហើយក្នុងសន្ធិសញ្ញានិងអនុសញ្ញាទាំងឡាយ ក្នុងពេលមុន ឱ្យទៅជាកើតហេតុនោះ ។

ॐ

ॐ ॐ

# សេចក្តីសន្និដ្ឋាន

តាមយុត្តិធម្មសាស្ត្រ បញ្ហាប្រាសាទព្រះវិហាមានលក្ខណៈងាយបំផុត ហើយអាចបង្រួមមកនៅត្រឹមតែជាការសង្កេតពីរយ៉ាងដូចតទៅ ៖

## ការសង្កេតឃើញទី១

អនុសញ្ញាចុះ**ថ្ងៃទី ១៣កុម្ភៈ១៩០៤** ដែលមានការបញ្ជាក់បន្ថែមក្នុងសន្ធិសញ្ញាចុះថ្ងៃទី **២៣មិនា១៩០៧** ហើយដែលកិច្ចព្រមព្រៀងនាក្រុងវ៉ាស៊ីនតុនឆ្នាំ១៩៤៦ បានត្រឡប់ធ្វើឱ្យជាធរមានឡើងវិញនោះ កំណត់ព្រំប្រទល់ដែនរវាងប្រទេសកម្ពុជានិងប្រទេសថៃ ។

អត្ថបទទាំងនេះ រាប់រៀបចំណុចធំៗនៃព្រំប្រទល់ដែន ហើយបានប្រគល់ឱ្យគណៈកម្មការចំរុះជាអ្នកកំណត់បន្ទាត់ព្រំប្រទល់ដែនដ៏យ៉ាងត្រឹមត្រូវ ។ ការងារនៃគណៈកម្មការចំរុះខាងលើ ដែលប្រព្រឹត្តិទៅអស់រយៈពេលជាច្រើនឆ្នាំបានសំរេចធ្វើសេចក្តីកត់ហេតុនិងស្ថាបនាផែនទីទាំងឡាយ ។

គឺផែនទីទាំងនេះហើយ ដែលទុកជាឯកសារដ៏យ៉ាងជាក់ច្បាស់ ព្រមទាំងអាចប្រើការជាស្ពានទៅបាន ។ ចំពោះរឿងនេះ ឯកសារជាសារៈគឺផែនទី ១/២០០.០០០ ដែលដាក់សារបានថា **"ផែនទីនៃគណៈកម្មការកំណត់ព្រំប្រទល់ដែនរវាងឥណ្ឌូចិននិងប្រទេសសៀម"** (សន្លឹកត្រង់ភ្នំដងរែក) ដែលរដ្ឋាភិបាលនៃប្រទេសថៃឥតមានតវ៉ា អំពីការត្រឹមត្រូវដ៏ពិតប្រាកដនេះ ហើយដែលរដ្ឋាភិបាលនៃប្រទេសថៃខ្លួនឯងបានទាំងបញ្ជាក់បន្ថែមលើការត្រឹមត្រូវទៀងទាត់ដោយផែនទីរបស់ខ្លួន ១/២០០.០០០ ខាងលើនេះទៀតផង ។

ផែនទីទាំងនេះ ចុះនិទ្ទេសថា តំបន់ព្រះវិហារស្ថិតនៅក្នុងដែនដីខ្មែរ ។

ឯកសារខាងផែនទីនេះ ចាត់ទុកជាឧបសម្ពន្ធនៃសន្ធិសញ្ញា និងជាការពង្រីកនៃសន្ធិសញ្ញានេះផង ។ ដូច្នេះតាមយុត្តិធម្មសាស្ត្រ ឯកសារខាងផែនទីរលាយចូលគ្នាជាមួយសន្ធិសញ្ញា ហើយមានតម្លៃដូចគ្នា នឹងអត្ថបទនៃសន្ធិសញ្ញានោះផង ។

ដូច្នេះតាមច្បាប់អន្តរជាតិ រឿងនេះត្រូវតែប្រព្រឹត្តិទៅយ៉ាងនេះឯង បើកាលណាសន្ធិសញ្ញាណា មួយទទួលការបំពេញបន្ថែមពីលើ គឺឧបសម្ព័ន្ធឬឯកសារខាងការពង្រីកហើយ ។

វត្ថុធាតុផ្សេងៗទាំងឡាយនោះ ទោះបីមានឈ្មោះហៅដូចម្តេចក្តី ឬទោះបីមានចុះកាលបរិច្ឆេទយ៉ាងដូចម្តេចក្តី ត្រូវចាត់ទុកជាវត្ថុមួយដែលមិនអាចបំបែកចេញបាន ហើយតម្លៃខាងយុត្តិធម្មសាស្ត្រនៃវត្ថុនេះ ត្រូវមានសភាពស្មើគ្នា និងជាឯកសណ្ឋាន កុំឱ្យតែមានបទបញ្ញត្តិផ្ទុយ ។

ដូច្នេះ សន្ធិសញ្ញាណាមួយដែលដំណាងខាងការទូត ឬខាងរដ្ឋាភិបាលធ្វើកិច្ចចរចាហើយ ពិតជាមិនអាចសំរួលបញ្ហាទាំងស្រុងបាន ជាបញ្ហាដែលរឿងខាងលើនេះបានចោទមក ។ តាមធម្មតា តែងមានឯកសារឧបសម្ព័ន្ធនៅជាមួយនឹងរឿងនេះ ឯឯកសាឧបសម្ព័ន្ធគឺអ្នកបច្ចេកទេសទាំងឡាយបានស្ថាបនាឡើង ហើយដែលអាចបើកឱកាសឱ្យអនុវត្តន៍យ៉ាងជាក់ច្បាស់ បានដោយងាយ ។

និតិក្រមនេះ តែងមានរឿងកំណត់ព្រំប្រទល់ដែនជាប់នៅជាមួយផងជានិច្ច ។ ចំពោះរឿងនេះ អនុសញ្ញា បារាំង-សៀម នៅឆ្នាំ១៩០៤-១៩០៧ មាននៅក្នុងផែនការខាងទំនៀមទំលាប់អន្តរជាតិ ដែលត្រូវគ្នាសុទ្ធសាធនឹងរឿងហេតុទាំងឡាយក្នុងអតីតកាល ហើយដែលត្រូវគ្នានឹងអត្ថបទទាំងឡាយដែលកើត មានតាំងពីក្នុងឱកាសជាច្រើនលើកមកហើយនោះ ។

ॐ
ॐ ॐ

ដូច្នេះគឺជាការមិនពិតទេ ដែលក្ងួចកាន់ដូចជារដ្ឋាភិបាលប្រទេសថៃបានធ្វើជាច្រើនលើកថា បញ្ហាព្រះវិហារមិនមែនជាកម្មវត្ថុនៃការសំរុះសំរួលក្នុងពេលមុនអ្វីមួយឡើយ រវាងប្រទេសបារាំងនិងប្រទេសសៀម ហើយថាតំបន់នេះជាកម្មវត្ថុនៃកិច្ចតវ៉ាជាធម្មតារវាងប្រទេសទាំងពីរ ។

ដែលរដ្ឋាភិបាលបារាំងទៅជាតវ៉ាជាច្រើនលើកអំពីរឿងនេះ ចំពោះរាជការសៀម គឺដោយហេតុមកតែអំពីការប្រព្រឹត្តិនិងការជិះជាន់របស់រាជការសៀមតែម៉្យាងប៉ុណ្ណោះ មិនមែនតវ៉ាដើម្បីសំរួលបញ្ហាដែលអនុសញ្ញាឆ្នាំ១៩០៤ និងផែនទីដែលស្ថាបនាឡើងដោយអនុវត្តន៍អនុសញ្ញានេះ បានសំរេចរួចហើយនោះទេ ។

បញ្ហាដែលត្រឡប់ទៅជាស្មុគ្រស្មាញពីព្រោះតែរាជការប្រទេសថៃមិនព្រមប្រតិបត្តិតាមសន្ធិសញ្ញា ។

# ការសង្កេតឃើញទីពីរ

អនុសញ្ញាបារាំង-សៀមឆ្នាំ១៩០៤ សន្ធិសញ្ញាបារាំង-សៀមឆ្នាំ១៩០៧ ដែលកិច្ចព្រមព្រៀងនាក្រុងវ៉ាស៊ីនតុនឆ្នាំ ១៩៤៦ បានត្រឡប់ដាក់ឱ្យជាធរមានឡើងវិញនោះ អនុវត្តន៍ទៅដោយខ្លួនឯង ចំពោះការទាក់ទងរវាងប្រទេសកម្ពុជា និងប្រទេសថៃ ។

មិនគួរគប្បីនឹងអះអាងថា សន្ធិសញ្ញានិងអនុសញ្ញាអន្តរជាតិទាំងនោះ មានចំពោះតែប្រទេសបារាំង ហើយមិនមានចំពោះប្រទេសកម្ពុជានោះបានឡើយ ព្រោះប្រទេសបារាំងជាអាណាព្យាបាលលើប្រទេសកម្ពុជា មុនដែលប្រទេសនេះ [កម្ពុជា]បានឯករាជ្យ ។

មុនបានឯករាជ្យ ប្រទេសកម្ពុជាមានលក្ខន្តិកៈជារដ្ឋនៅក្នុងអាណាព្យាបាល ។ តាមច្បាប់អន្តរជាតិ មានការយល់ព្រមជាឯកច្ឆ័ន្ទថា រដ្ឋដែលស្ថិតនៅក្នុងអាណាព្យាបាល ត្រូវរក្សាបុគ្គលិកលក្ខណៈអន្តរជាតិរបស់ខ្លួនទុក ហើយប្រគល់ឱ្យរដ្ឋដទៃណាមួយនូវសិទ្ធិធ្វើកិច្ចប្រាស្រ័យទាក់ទងក្រៅប្រទេសជំនួសខ្លួន ។ ដូច្នេះ គឺក្នុងនាមនិងដើម្បីជាប្រយោជន៍នៃប្រទេសកម្ពុជានេះហើយ បានជាប្រទេសបារាំងសំរេចសន្ធិសញ្ញាឆ្នាំ១៩០៤-១៩០៧ និង១៩៤៦ ក្នុងឋានៈជាអ្នកកាន់កាប់ការនៃព្រះរាជអាណាចក្រកម្ពុជា ។ សន្ធិសញ្ញាទាំងនេះបានរំលឹកយកមកអនុវត្តន៍បានឯងៗ ចំពោះប្រទេសកម្ពុជា ព្រោះប្រទេសនេះបានទៅជារដ្ឋឯករាជ្យហើយ ។

ॐ
ॐ ॐ

# ឧបសម្ព័ន្ធ

# ប្រាសាទព្រះវិហារ

# អំពីផែនទី




ផែនទី១ ខ្នាត ១/២០០.០០០ ដែលដាក់សារបានថា

**"ផែនទីនៃគណៈកម្មការកំណត់ព្រំប្រទល់ដែនរវាងឥណ្ឌូចិននិងប្រទេសសៀម"** (សន្លឹកត្រង់ភ្នំដងរែក)

ផែនទីនេះកំណត់នូវជ័យជំនះរបស់ខ្មែរលើប្រទេសសៀម មានដំកល់ទុកនៅតុលាការអន្តរជាតិ ទីក្រុងឡាហេ្ស

(ទំព័រទី១១២ដល់ទំព័រទី១១៥) នៃសេចក្តីសំរេចចិត្តរបស់តុលាការ ។

( ផែនទីទាំងបួនផ្ទាំងនេះស្រង់ចេញមកពីឯកសារនៃតុលាការអន្តរជាតិនៅទីក្រុងឡាហេ្ស

យកមកដាក់បញ្ចូលបន្ថែមក្នុងឯកសារនេះដោយ *គេហដ្ឋានផ្សាយអប្សរា* )




ផែនទីទី២

ខ្នាត ១/២០០.០០០ ដែលដាក់សារបានថា

**"ផែនទីនៃគណៈកម្មការកំណត់ព្រំប្រទល់ដែនរវាងឥណ្ឌូចិននិងប្រទេសសៀម"** (សន្លឹកត្រង់ភ្នំដងរែក)







ផែនទីខ្នាត ១/២០០.០០០ ដែលដាក់សារបានថា“**ផែនទីនៃគណៈកម្មការកំណត់ព្រំប្រទល់ដែនរវាងឥណ្ឌូចិននិងប្រទេសសៀម**”

*(សន្លឹកត្រង់ភ្នំដងរែក)*

# អំពីប្រវត្តិ

**ព្រះបាទយសោវរ្ម័ន** ជាព្រះមហាក្សត្រិយ៍ខ្មែរ ដែលទ្រង់ជាអ្នកកសាងអង្គរ ពិតជាព្រះអង្គបានកសាងប្រាសាទព្រះវិហារ ក្នុងរយៈឆ្នាំខាងចុងនៃសតវត្សរ៍ទី៩ ។ ប្រាសាទព្រះវិហារនេះកសាងឡើងដើម្បីឧទ្ទិសថ្វាយ **ព្រះសិខារីស្វរៈ** គឺថា**ព្រះសិវៈ**ជាអម្ចាស់ដ៏ខ្ពង់ខ្ពស់បំផុត ។ ប៉ុន្តែប្រាសាទសព្វថ្ងៃទាំងមូលមានចុះកាលបរិច្ឆេទពីពាក់កណ្តាលសតវត្សរ៍ទី១១មក ។ កាល**ព្រះបាទសុរិយវរ្ម័នទី១** ទ្រង់បានស្ថាបនាអំណាចដ៏យ៉ាងរឹងប៉ឹងលើប្រទេសកម្ពុជាហើយ ទ្រង់ព្រះបញ្ជាឱ្យកសាងប្រាសាទធំៗ នៅព្រះបរមរាជវាំងអង្គរ ព្រមទាំងប្រាសាទនៅភ្នំជីសូរ និងព្រះវិហារ ដែលសំណង់បានចាប់ផ្តើមនៅឆ្នាំ១០១៨ ។ នៅទីបំផុតសតវត្សរ៍ទី១១ និងក្នុងរយៈឆ្នាំដំបូងនៃសតវត្សរ៍ទី១២ ព្រះរាជាខ្មែរព្រះនាម**ជ័យវរ្ម័នទី៦** បានទ្រង់ចាប់កសាងជាថ្មីទៀត ហើយ**ព្រះចៅសុរិយវរ្ម័នទី២** ដែលទ្រង់ជាអ្នកកសាងប្រាសាទអង្គរវត្តនោះ បានចាប់សង់បន្តមកទៀត ក្នុងកំឡុង២៥ឆ្នាំជាខាងដើមនៃសតវត្សរ៍ទី១២ ។ ការរៀបចំសំណង់ជាថ្មីឡើងវិញខ្លះៗ ដែលគេបានសង្កេតឃើញក្នុងព្រះវិហារនោះ ប្រាកដជាមានកាលបរិច្ឆេទនៅសម័យនៃការកសាងផ្សេងៗនោះ ។



# ផែនការនៃព្រះវិហារ

ប្រាសាទព្រះវិហារ សង់ឆ្ពោះទៅទិសខាងជើង ។ តួប្រាសាទកណ្តាលដែលសង់នៅចំត្រង់គែមខ្ពង់រាប មានកំផែងព័ទ្ធជុំវិញតែមួយជាន់ ។ ប៉ុន្តែទោះបីឥតមានកំផែងដទៃក៏ដោយ ប្រាសាទនេះគង់មានគោប៉ូរៈ៥ដែរ ។

**គោប៉ូរៈទី១** គឺជាគោប៉ូរៈនៃកំផែងទី១ ដែលភ្ជាប់ទៅនឹងទីព្រះលានតាំងនៅពីខាងមុខ ឆ្ពោះទៅទិសខាងជើង ។

**គោប៉ូរៈទីពីរ** សំរាប់បើកឱ្យចេញពីទីព្រះលាន ហើយទៅដល់ជណ្តើរមួយតាំងនៅខាងជើង រួចមានតួផ្ទៃថ្នល់មួយ មាននាគនៅសងខាង ។

នៅទីបំផុតនៃថ្នល់នេះ គេឃើញមាន**គោប៉ូរៈទី៣** រួចមានជណ្តើរថ្មីមួយហើយនឹងថ្នល់មួយ ទៅដល់**គោប៉ូរៈទី៤** គឺថាឆ្ពោះទៅទិសខាងជើងជាធម្មតា ។

ពី**គោប៉ូរៈទី៤**ទៅ មានថ្នល់មួយយ៉ាងវែងឆ្ពោះទៅ**គោប៉ូរៈទី៥** ដែលមានជណ្តើរមួយពីខាងមុខ ។

ពីខាងកើតនិងពីខាងលិចនៃកំផែងទី១ មានសង់អាគារពីរខ្នងភ្ជាប់នៅនោះ ។ ក្នុងទីលានខាងមុខកំផែងទី១ មានបណ្ណាល័យពីរនៅព័ទ្ធពីខាងមុខ**គោប៉ូរៈទី១** ។ មានសាលវែងពីរសន្ធឹងពីខាងជើងទៅខាងលិច ត្រង់**គោប៉ូរៈទី៣** ។

នៅពីខាងមុខឆៀងខាងកើត**គោបុ៉រៈទី៤** មានអាងទឹកមួយ (ស្រះស្រង់) ។



*ស្រះស្រង់ស្ថិតនៅខាងមុខ ឆៀងខាងខាងកើត* ***គោបុ៉រៈទី៤ ។*** *ស្រះនេះទុកសំរាប់ប្រើប្រាស់នៅពេលមាន ពិធីសក្ការបូជាម្តងៗ ។*

# អំពីការរចនាតុបតែង

ក្បាច់រចនានៅប្រាសាទព្រះវិហារ គឺជាក្បាច់រចនាផ្នែកពីរបៀបនៅឃ្លាំង និងពីរបៀបប្រាសាទបាពួន ។ ប្រាសាទព្រះវិហារបានអភិរក្សទុកនូវការរចនាខាងរុក្ខជាតិ តាមរបៀបនៅឃ្លាំង ប៉ុន្តែជួនកាល មានបន្ថែមរឿងព្រេងបុរាណ ដែលជារឿងមានយ៉ាងច្រើននៅឯប្រាសាទបាពួន ។



*ប្រាសាទព្រះវិហារ (ការកូរសមុទ្រទឹកដោះ) នៃក្លោងទ្វារខាងលើ*

ប្រាសាទកណ្តាលមានបន្ទប់មួយនិងយ៉មួយ ។ យ៉នេះបាក់បែកខ្លះហើយ ។ ការរចនាតុបតែងមិនបានទាន់ហើយនៅឡើយទេ ។ តាមធម្មតា ការតុបតែងនៅពេញគោប៉ូរៈច្រើនធ្វើដោយផ្ចិតផ្ចង់គ្រាន់បើ ។ ក្បាច់ហោជាងមានរបៀបពីរបែបផ្សេងពីគ្នា ។ នៅតាមគែមព័ទ្ធជុំវិញក្បាច់នោះ មានចំឡាក់ជាទងរុក្ខជាតិប្រកបដោយស្លឹក មានរបៀបពត់ពេជារូបនាគ ។ គឺនៅឯព្រះវិហារនេះហើយដែលគេឃើញជាលើកដំបូងបង្អស់នូវក្បាច់ហោជាងដែលមានរូបក្បាលនាគនៅខាងចុង ។ នៅត្រង់ផ្ទៃហោជាងនេះ ជួនកាលគេរចនាជារឿង ជួនកាលគេរចនាជាស្លឹករុក្ខជាតិ ។ ហោរជាងមួយទៀតមានទ្រង់ទ្រាយជាត្រីកោណ ។ ក្បាច់ហោជាងនេះ មានដើមកំណើតពីសំណង់យ៉ាងងាយ ហើយពិតជាលាយឡំជាមួយដំបូលដែលមានតែពីផ្ទាំងខាងចុងបំផុតនៃដងក្តា មានរចនាតុបតែងជាក្បាច់គូថខ្មៅ ។ ហោជាងដ៏យ៉ាងល្អបែបនេះ មានលេចឃើញឡើងជាចុងក្រោយបង្អស់នៅឯព្រះវិហារ ។



នៅបណ្តាមេទ្វារខាងលើទាំងឡាយនៃព្រះវិហារ គេអាចសង្កេតឃើញមានពីរបែបផ្សេងពីគ្នា ។ មេទ្វារខ្លះមានទំនងដូចគ្នានឹងមេទ្វារខាងលើនៅឃ្លាំងយ៉ាងពិតប្រាកដ ។ មេទ្វារខាងលើរបៀបនេះមានសភាពដដែលៗ មិនសូវប្លែកពីគ្នាប៉ុន្មាន ។ មានរបៀបដទៃមួយទៀតគឺជារបៀបនៃប្រាសាទបាពួន ហើយជាពិសេសគឺនៅត្រង់មេទ្វារខាងលើដែលមានឆ្លាក់រឿងផ្សេងៗ ។ មេទ្វារខាងលើដែលល្អជាងគេបង្អស់នោះ គឺមេទ្វារនៃប្រាសាទកណ្តាលដែលមានរចនាលំអដោយរូបព្រះវិស្ណុដេកលើនាគរាជ ។



គួរលើកយកសត្វដែលមានរចនានៅទីនោះមកពោលដែរ ។ សត្វសឹង្ហដែលគេកសាងឡើងដោយ ធ្វើគូថឱ្យបះឡើងខ្ពស់បន្តិច ប្រាប់ដំណឹងយ៉ាងជាក់ច្បាស់ថា គេរចនាក្នុងសម័យសតវត្សទី១២ ។ ឯពួកនាគក៏មានការប្លែកជាច្រើន ។ គេរចនានាគតាមលំនាំធម្មជាតិ ឥតឱ្យមានពាក់ក្បាំងឡើយ ហើយបញ្ចេញ រចនាសំដែងអាការៈយ៉ាងកាចសាហាវ ។ ឯនាគដែលកសាងឡើងជាបង្កាន់ដៃនោះ មិនឱ្យវានៅលើដីទេ គឺមានដុំថ្មទ្រពីក្រោម ។

ព្រះវិហារជាប្រាសាទមួយប្លែកអស្ចារ្យរបស់សិល្បៈខ្មែរ ព្រោះផែនការនៃប្រាសាទនេះមានសភាពសមរម្យទៅតាមសភាពទីកន្លែង ព្រោះការរចនាតុបតែងនៃប្រាសាទនេះទៀត ក៏បណ្តាលឱ្យសង្កេតឃើញថាជាការរចនា នៅជាចន្លោះយ៉ាងច្បាស់ រវាងការរចនានៅឃ្លាំង និងការរចនានៅប្រាសាទបាពួន ។ ૐ

***កំណត់ហេតុនៃអ្នកចំឡង :***

✹ ឯកសារនេះបានចំឡងឡើងវិញទាំងស្រុងត្រឹមត្រូវទៅតាមឯកសារដើមដែលគ្មានឈ្មោះអ្នកនិពន្ធ គ្មានចុះថ្ងៃខែពីតប្រាកដ ប៉ុន្តែមានដាក់រូប "ព្រះសិង្ហារ" ដែលជានិម្មិត្តរូបដំណាងព្រះរាជាណាចក្រកម្ពុជា(រហូតដល់មុនខែមិនាឆ្នាំ១៩៦០) ។ រូបនិងផែនទីបានត្រូវយកមកដាក់បញ្ចូលឡើងវិញដោយបន្ថែមរូបខ្លះដែលឯកសារដើមមានភាពមិនច្បាស់ ។ យើងមិនបានស្រាវជ្រាវថាតើឯកសារនេះមានជាភាសាបារាំឬអង់គ្លេសនោះទេ ។

✹ ពាក្យបណ្តឹង ការតវ៉ា ការទាមទារទាំងប៉ុន្មានធ្វើឡើងដោយរាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា ការកាត់សេចក្តីរបស់តុលាការអន្តរជាតិទីក្រុងឡាហ្អេស្គីអំពី "ករណីយព្រះវិហារ" មានទាំងអស់ ៣៤២០ទំព័រ ចែងជាភាសាបារាំងនិងភាសារអង់គ្លេស ។ ឯកសារទាំងពីរភាសានេះ បានត្រូវចំឡងឡើងវិញ បោះពុម្ពជាសៀវភៅ ព្រមទាំងដំកល់ទុកត្រឹមត្រូវតាមច្បាប់នៅ ***បណ្ណាល័យជាតិនិងមណ្ឌលដំកល់ឯកសារកេបិក*** និងនៅ *បណ្ណាល័យជាតិកាណាដា* រួចហើយ ។ ឯកសារនេះនៅមិនទាន់បានបកប្រែជាភាសាជាតិនៅឡើយទេ ។

✹ ដើម្បីជ្រាបច្បាស់អំពីឯកសារទាំងប៉ុន្មាន (៣៤២០ទំព័រ) ដែលបានរៀបរាប់ខាងលើ រួមមានទាំងការកាត់សេចក្តីរបស់តុលាការអន្តរជាតិទីក្រុងឡាហ្អេស្គីអំពី "ករណីយព្រះវិហារ" សូមអញ្ជើញស្រាវជ្រាវដោយចុច :
International Court of Justice ឬ Cour International de Justice តាមរយៈ Yahoo ឬ Google

**ចម្លងឡើងវិញតាមច្បាប់ដើម**
***ដោយ ម៉ុក គៀង***
**អូតាវ៉ា, កាណាដា ឆ្នាំ ២០០១**

**ÉDITIONS APSARA**
Montréal, Québec H1W 3G7
Téléphone : 514-596-0896
Télécopieur : 514-596-1423
Courriel / Email : apsara16@sympatico.ca

# សេចក្តីកែដំរូវ

ក្នុងកំរងឯកសារ៖ **កំណត់អំពីបញ្ហាព្រះវិហារ** រៀបចំដោយ
**គណៈបេសកកម្មអចិន្ត្រៃយ៍នៃប្រទេសកម្ពុជាប្រចាំសហប្រជាជាតិ**
*ដែល ខេមរជាតិ បានផ្សាយជូនថ្មីៗ*
*យើងសូមអនុញ្ញាតធ្វើការកែដំរូវដូចតទៅ*

***ទំព័រទី២៨ បន្ទាត់ទី៤ ពីលើចុះក្រោម ឃ្លានៅដើមបន្ទាត់***
***សូមមេត្តាអានថា: មិនាឆ្នាំ១៩៧០ ។***

*យើងសូមអភ័យទោសចំពោះកំហុសដោយអចេតនានេះ ។*


**ខេមរជាតិ**

khemarajati@sympatico.ca